មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

# វគ្គទី៨

# ប្រធានបទ៖ សំណុំរឿងពាក់ព័ន្ធនឹង លោក ហ្វ្រែង (the Frank Case) និង ព័ត៌មានថ្មីៗទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អំពីការបែងចែកស្រូវនៅក្នុងរបបខ្មែរក្រហម

*ដោយ ៖ វ៉េនឌុល ឌឹហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែតុលា ឆ្នាំ២០១៣*

ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៨ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗ នៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្ន

កស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា FM105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។

ការផ្សាយនៅក្នុងវគ្គទី៨នេះ ផ្តោតសំខាន់ទៅលើ ការកាត់ទោស លោក ហាន់ ហ្វ្រែង (Hans Frank) ដែលជាអតីតសមាជិករបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ដោយតុលាការយោធាអន្តរជាតិ (International Military Tribunal) បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់ និងការបកស្រាយរបស់តុលាការទាក់ទងនឹងការអត់ឃ្លាន ។ នៅក្នុងការផ្សាយក្នុងវគ្គទី៨នេះ យើងខ្ញុំក៏លើកយកព័ត៌មានថ្មីៗទាក់ទងនឹងភស្តុតាងបន្ថែមទៀត ដែលនិយាយអំពីការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយយោងទៅលើសក្ខីកម្មរបស់ រស់ ស៊ុយ ដែលធ្វើឡើងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកាលពី ខែមេសា ឆ្នាំ២០១៣ ។

## សេចក្តីផ្តើមៈការអត់ឃ្លានក្នុងការចូលកាន់កាប់ប្រទេសប៉ូឡូញក្នុងអំឡុងសង្គ្រាមលោកលើកទី២

បន្ទាប់ពីសង្គ្រាមលោកលើកទី២បានបញ្ចប់ ប្រទេសសម្ព័ន្ធមិត្តដែលទទួលបានជ័យជំនះ រួមមាន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងរុស្ស៊ី បានបង្កើតតុលាការមួយនៅទីក្រុងនូរឹមប៊ឺក (Nuremberg) ក្នុងប្រទេសអាល្លឺម៉ង់ ដែលបាននាំយកសមាជិកជាន់ខ្ពស់មួយចំនួនរបស់ បក្សណាហ្ស៊ីអាល្លឺម៉ង់ មកធ្វើការជំនុំជម្រះពីបទឧក្រិដ្ឋកម្មអន្តរជាតិ ។ ក្នុងនោះលោក ហាន់ ហ្វ្រែង (Hans Frank) ដែលមានមុខតំណែងជាប្រធានរដ្ឋបាលស៊ីវិល និងក្រោយមកទៀតជាអ្នកគ្រប់គ្រងទូទៅ ដែលកាន់កាប់ប្រទេសប៉ូឡូញ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ត្រូវបានតុលាការយោធាអន្តរជាតិ ធ្វើការជំនុំជម្រះទោស ។ លោក ហ្វ្រែង គឺជាអ្នកទទួលបន្ទុកលើកិច្ចការផ្សេងៗរបស់អាល្លឺម៉ង់ នៅក្នុងប្រទេសប៉ូឡូញ ក្នុងអំឡុងពេលសង្គ្រាម ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់អាល្លឺម៉ង់ មកលើប្រទេសប៉ូឡូញ ប្រជាជនប៉ូឡូញជាច្រើនត្រូវបានបង្ខំឲ្យធ្វើការច្រើនម៉ោង ដើម្បីផលិតទំនិញផ្សេងៗ ដែលក្នុងនោះរួមមានស្បៀងអាហារ ដើម្បីផ្គត់ផ្គង់ដល់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។ ស្របពេលជា

មួយគ្នានេះដែរ ប្រជាជនប៉ូឡូញទទួលបានរបបអាហារតិចតួចបំផុត ដោយសារតែ ស្បៀងអាហារភាគច្រើនត្រូវបានផ្គត់ផ្គង់ដល់យោធាអាល្លឺម៉ង់ក្នុងការធ្វើសង្គ្រាម ។ បន្ទាប់ពីបានពិចារណាទៅលើតួនាទីរបស់ លោក ហ្វ្រែង ក្នុងការមើលការខុសត្រូវរបស់អាល្លឺម៉ង់ទៅលើប្រទេសប៉ូឡូញ ចៅក្រមតុលាការយោធាអន្តរជាតិ បានរកឃើញថា លោក ហ្វ្រែង ពិតជាមានទោសទាក់ទងនឹងបទចោទប្រកាន់ផ្សេងៗ រួមមាន ទំនួលខុសត្រូវរបស់ លោក ហ្វ្រែង ទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការសម្លាប់ អំពើឃាតកម្ម ការយកប្រជាជនប៉ូឡូញធ្វើជាទាសករ ការនិរទេស និងសកម្មភាពសាហាវព្រៃផ្សៃផ្សេងទៀត ដែលប្រឆាំងនឹងប្រជាជនប៉ូឡូញ ។ ការផ្តន្ទាទោសទាំងនេះ ផ្តោតសំខាន់ទៅលើតួនាទីរបស់ លោក ហ្វ្រែង ដែលបានប្រព្រឹត្តអំពើសាហាវព្រៃផ្សៃទៅលើប្រជាជនប៉ូឡូញ ដើម្បីផ្គត់ផ្គង់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។

នៅក្នុងសំណុំរឿង លោក ហ្វ្រែង ចៅក្រមបានកត់សម្គាល់ឃើញថា នៅក្នុងគោលនយោបាយរបស់ បក្សណាហ្ស៊ីអាល្លឺម៉ង់ លោក ហ្វ្រែង បានថ្លែងថា "ប្រទេសប៉ូឡូញគួរតែបានចាត់ទុកដូចជាប្រទេសដែលស្ថិតក្រោមអាណានិគម ហើយប្រជាជនប៉ូឡូញនឹងក្លាយជាទាសករ របស់ចក្រភពអាល្លឺម៉ង់" ។ ចៅក្រមបានសន្និដ្ឋានថា "ភស្តុតាងទាំងឡាយបានសបញ្ជាក់ឲ្យឃើញពី គោលនយោបាយរបស់អាល្លឺម៉ង់ ក្នុងការកាន់កាប់ប្រទេសប៉ូឡូញ ដែលផ្អែកទៅលើការបំផ្លិចបំផ្លាញប្រជាជាតិប៉ូឡូញទាំងមូល និងការកេងយកផលប្រយោជន៍ពីប្រជាជន និងសេដ្ឋកិច្ចរបស់ប៉ូឡូញ ដើម្បីបម្រើដល់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។ ជនដែលប្រឆាំងទាំងអស់ត្រូវបានកម្ទេចចោលយ៉ាងសាហាវឃោរឃៅបំផុត" ។ ជាលទ្ធផលនៃការបំផ្លិចបំផ្លាញដោយគ្មានមេត្តានេះ តុលាការបានកត់សម្គាល់ថា លក្ខខណ្ឌធ្វើការដ៏អាក្រក់ និងការដកហូតសិទ្ធិទទួលបានចំណីអាហារ បានបង្កឲ្យប្រជាជនប៉ូឡូញស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយសារជម្ងឺ និងការអត់ឃ្លាន ។ តុលាការក៏បានរកឃើញថាៈ

> "តម្រូវការផ្នែកសេដ្ឋកិច្ច ដែលដាក់ទៅលើប្រទេសប៉ូឡូញ គឺច្រើនលើសពីអ្វីដែលជាតម្រូវការរបស់កងទ័ព ហើយតម្រូវការនេះមិនសមមាត្រទៅនឹងធនធានរបស់ប្រទេសប៉ូឡូញឡើយ ។ ទិន្នផលស្បៀងរបស់ប៉ូឡូញដែលត្រូវបានដឹកតាមកប៉ាល់ទៅកាន់ប្រទេសអាល្លឺម៉ង់ក្នុងទ្រង់ទ្រាយធំ ដែលបង្កឲ្យមានការថយចុះបរិមាណស្បៀងសម្រាប់ប្រជាជនប៉ូឡូញ ដែលជាកត្តាបង្កឲ្យមានគ្រោះអត់ឃ្លាន និងជម្ងឺរាតត្បាតបានរីករាលដាលនៅទូទាំងប្រទេស ។ ស្បៀងមួយចំនួន ត្រូវបានយកទៅចិញ្ចឹមតែប្រជាជនដែលធ្វើការងារកសិកម្មប៉ុណ្ណោះ ។ ចំណែកឯ ប្រជាជនមួយចំនួនផ្សេងទៀតមិនត្រូវបានយកចិត្តទុកដាក់ឡើយ ។ មេធាវីការពារក្តីរបស់ លោក ហ្វ្រែង

បានលើកឡើងថា ការឈឺចាប់មួយចំនួនបានកើតឡើង ដោយសារតែការហែកហួរនៃសង្គ្រាម និងវិបត្តិសេដ្ឋកិច្ច ។ ប៉ុន្តែ ទំហំនៃឈឺចាប់ទាំងនោះបានកើនឡើងថែមទៀត ដោយសារតែគោលនយោបាយបំផ្លិចបំផ្លាញផ្នែកសេដ្ឋកិច្ចរបស់អាល្លឺម៉ង់» ។

ការប្រើប្រាស់កម្លាំងពលកម្មប្រជាជនប៉ូឡូញរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ មានលក្ខណៈស្រដៀងគ្នាទៅនឹងខ្មែរក្រហម ដែលបានប្រើប្រាស់កម្លាំងពលកម្មប្រជាជនកម្ពុជាក្នុងការបម្រើដល់បដិវត្តន៍របស់ខ្លួនដែរ ។ នៅក្នុងស្ថានភាពទាំងពីរ ទាំងបក្សណាហ្ស៊ីអាល្លឺម៉ង់ និងខ្មែរក្រហម ប្រជាជនស៊ីវិលទទួលបាននូវសិទ្ធិមួយចំនួនតូចតែប៉ុណ្ណោះ ដូចជា ចំណីអាហារជាដើម ។ ទាំងនៅក្នុងប្រទេសប៉ូឡូញ និងប្រទេសកម្ពុជា ប្រជាជនស៊ីវិលទទួលរងនូវលក្ខខណ្ឌរស់នៅដ៏អាក្រក់ រួមមាន គ្រោះអត់ឃ្លាន ជម្ងឺ និងការអត់អាហារ ដែលឈានទៅដល់ការស្លាប់ប្រជាជនក្នុងទ្រង់ទ្រាយធំ ។ ជាចុងក្រោយ តុលាការបានរកឃើញថា “លោក ហ្វ្រែង ជាបុគ្គលមួយរូប ដែលបានដឹង និងមានឆន្ទៈក្នុងការប្រព្រឹត្តិទង្វើឃោរឃៅក្នុងប្រទេសប៉ូឡូញ ។ មិនតែប៉ុណ្ណោះ ការធ្វើទុក្ខបុកម្នេញផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសប៉ូឡូញបានបង្កឲ្យប្រជាជនយ៉ាងច្រើនស្លាប់ដោយសារការអត់ឃ្លាន ។ លោក ហ្វ្រែង ក៏ជាប់ពាក់ព័ន្ធនឹងការនិរទេសប្រជាជនប៉ូឡូញជាង១លាននាក់ទៅកាន់ប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើជាទាសករ និងជាប់ពាក់ព័ន្ធទៅនឹងសម្លាប់ជនជាតិជ្វីព (Jews) យ៉ាងហោចណាស់៣លាននាក់» ។

សេចក្តីសម្រេចរបស់តុលាការយោធាអន្តរជាតិ ប្រឆាំងនឹង លោក ហ្វ្រែង ជាឧទាហរណ៍មួយដែលបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចយកមកជំនុំជម្រះបុគ្គលទាំងឡាយណា ដែលរួមចំណែកក្នុងការបង្កឲ្យមានការអត់ឃ្លានចំពោះប្រជាជនស៊ីវិល ដែលបណ្តាលឲ្យប្រជាជនយ៉ាងច្រើនត្រូវស្លាប់ ក្នុងលក្ខខណ្ឌរស់នៅមិនសមជាមនុស្ស និងការរើសអើងផ្សេងៗ ។

ការផ្តន្ទាទោស លោក ហ្វ្រែង ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ក្នុងទ្រង់ទ្រាយធំ បានបង្ហាញថា បើទោះបីជាជនជាប់ចោទមិនបានប្រព្រឹត្តិអំពើឧក្រិដ្ឋទៅបុគ្គលណាម្នាក់ដោយផ្ទាល់ក៏ដោយ ក៏ការសម្លាប់ក្នុងទ្រង់ទ្រាយធំនោះ បានបង្ហាញយ៉ាងច្បាស់ថា ការអត់ឃ្លានបានកើតឡើងចំពោះប្រជាជនស៊ីវិលជាទូទៅ ។ នៅក្នុងករណីនៃការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ការចោទប្រកាន់ចំពោះការសម្លាប់រង្គាល អាចបង្ហាញពីការសម្រេចចិត្តរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងទីក្រុងភ្នំពេញ ដែលបានបង្កឲ្យប្រជាជនតាមទីជនបទទូទាំងប្រទេសស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ។

តុលាការយោធាអន្តរជាតិ ក៏បានរកឃើញផងដែរថា លោក ប្រែហ្វង មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត ដូចជា ការចូលរួមនៅក្នុង "ផែនការចុងក្រោយ" (the Final Solution) របស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ក្នុងការសម្លាប់ជនជាតិជ្វីពទាំងអស់ដែលរស់នៅអឺរ៉ុប ។ តុលាការរកឃើញថា នៅក្នុង "ផែនការចុងក្រោយ" របស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ជនជាតិជ្វីពដែលរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយអាល្លឺម៉ង់ទាំងអស់ "ត្រូវបានបង្ខំឲ្យរស់នៅដាច់ដោយឡែក និងក្លាយជាជនរងគ្រោះនៃច្បាប់រើសអើង ។ មិនតែប៉ុណ្ណោះ ជនជាតិជ្វីពទាំងអស់នោះ ត្រូវបានដកហូតសិទ្ធិទទួលបានចំណីអាហារ ទទួលរងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ជាលក្ខណៈប្រព័ន្ធ" ។ ការធ្វើទុក្ខបុកម្នេញរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ទៅលើជនជាតិជ្វីព មានលក្ខណៈស្រដៀងគ្នាទៅនឹងការដឹកនាំរបស់ខ្មែរក្រហមដែលបានបង្ហាញពីការស្អប់ខ្ពើមទៅលើប្រជាជនថ្មី ។ ប្រជាជនថ្មី ជាមុខសញ្ញាមួយក្នុងចំណោមប្រជាជនទូទាំងប្រទេស ដែលទទួលបាននូវលក្ខខណ្ឌរស់នៅតិចតួចបំផុត ដូចជាអាហារ ជម្រក ការថែទាំសុខភាព និងការសម្រាកជាដើម ។

## ភស្តុតាងថ្មីៗដែលរកឃើញនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលពាក់ព័ន្ធនឹងការចែកចាយស្រូវនៅក្នុងរបបខ្មែរក្រហម

ដូចដែលបានលើកឡើងនៅក្នុងវគ្គមុនៗរួចមកហើយ គ្មានរបាយការណ៍មួយណាបានបង្ហាញពីចំនួនស្រូវ ដែលបានផលិតនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម និងចំនួនស្រូវដែលបាននាំចេញទៅក្រៅប្រទេសនោះទេ ។ បើទោះជាមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើននាក់រាប់បញ្ចូលទាំងកម្មាភិបាលខ្មែរក្រហម បានលើកឡើងក្នុងបទសម្ភាសន៍ថា ខ្លួនបានឃើញចំនួនស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានបក្សកម្មុយនីស្តកម្ពុជាដកហូតពីប្រជាជន និងរៀបចំសម្រាប់ការនាំចេញក៏ដោយ ក៏អ្នកដែលរស់រានមានជីវិតទាំងនោះ មិនបានដឹងច្បាស់ពីដំណើរការនៃការនាំចេញពិតប្រាកដនោះទេ ។ ប៉ុន្តែ នៅក្នុង សក្ខីកម្មរបស់ លោក រស់ ស៊ុយ ដែលជាអ្នកគ្រប់គ្រងឃ្លាំងរបស់ខ្មែរក្រហម នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានស្រាយបំភ្លឺពីដំណើរការផលិតនិងការនាំចេញស្រូវនៅក្នុងរបបខ្មែរក្រហម ។ លោក រស់ ស៊ុយ បានប្រាប់ថា គាត់ធ្លាប់ធ្វើការក្នុងឃ្លាំងពីរកន្លែង ដែលស្ថិតនៅក្នុងនិងជុំវិញក្រុងភ្នំពេញ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គាត់គិតថា នៅពេលនោះយ៉ាងហោចណាស់ក៏មានឃ្លាំងស្រដៀងគ្នានេះមួយចំនួនផ្សេងៗទៀតមាននៅក្នុងតំបន់នេះដែរ ។ លោក រស់ ស៊ុយ បានបញ្ជាក់ថាមានតែស្រូវទេ ដែលត្រូវបានចែកចាយនៅក្នុងប្រទេស ។ ចំណែក ឃ្លាំងដែលគាត់គ្រប់គ្រង មានម៉ាស៊ីនកិនស្រូវ៤-៥គ្រឿង ដើម្បី ដំណើរការកិន

ស្រូវសម្រាប់បំពេញផែនការនាំចេញរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាមួយគ្នានេះដែរ លោក រស់ ស៊ុយ បានលើកឡើងថាស្រូវត្រូវបានរក្សាទុកនៅក្នុងឃ្លាំងសម្រាប់ការបញ្ជាទិញ នៅពេលដែលផលិតផលដទៃទៀត ដូចជា អំបិល និងស៊ីម៉ង់ ត្រូវបានចែកចាយពីឃ្លាំងរដ្ឋទៅកាន់ទីតាំងផ្សេងៗនៅក្នុងប្រទេសកម្ពុជា ។ សក្ខីកម្មរបស់ លោក រស់ ស៊ុយ មានភាពស្រដៀងគ្នាទៅនឹង ការលើកឡើងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត ដែលបានផ្តល់បទសម្ភាសន៍ជាមួយ លោកសាស្ត្រាចារ្យ បែន ឃៀនិន (Ben Kiernan) ដែលបានរៀបរាប់ថា ខ្លួនបានឃើញទូកដឹកស្រូវតាមទន្លេជាច្រើនធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ ។

ឯកសាររបស់បក្សកុំម្មុយនីស្តកម្ពុជាមួយចំនួន ដូចជាឯកសាររបស់គណៈកម្មាធិការពាណិជ្ជកម្មរដ្ឋ នៅក្រុងកំពង់សោម ក៏បានពិពណ៌នាស្រដៀងគ្នាទៅនឹងអ្វីដែល លោក រស់ ស៊ុយ បានលើកឡើងដែរ ។ ឯកសារទាំងនោះបានបង្ហាញពី «ចំណូលនិងចំណាយ» នៃទិន្នផលស្រូវ ដែលបានបញ្ជូនទៅមជ្ឈិមបក្ស ។ នៅលើឯកសារមួយចំនួន ត្រូវបានចុះហត្ថលេខាដោយ រឿង ដែល លោក រស់ ស៊ុយ បានអះអាងថាជាមេរបស់ខ្លួន ។ នៅក្នុងឯកសារនោះ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការដឹកជញ្ជូនស្រូវគ្រប់ទីកន្លែងនៅទូទាំងប្រទេស ទៅកាន់ឃ្លាំងនៅទីក្រុងភ្នំពេញ ដើម្បី កិន វេចខ្ចប់ រួចបញ្ជូនទៅកាន់កំពង់ផែសមុទ្រកំពង់សោម សម្រាប់ការនាំចេញទៅក្រៅប្រទេស ។ ដំណើរការទាំងអស់នោះ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ រឿង និងគណៈកម្មាធិការពាណិជ្ជកម្ម រដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនបានដឹងច្បាស់ពីចំនួនស្រូវ ដែលត្រូវបាននាំចេញពីប្រទេសកម្ពុជា នៅក្រោមការគ្រប់គ្រងនៃរបបខ្មែរនោះទេ ។ ប៉ុន្តែ បើយោងតាមភស្តុតាងដែលមានដូចជា ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែលនៅសេសសល់ និងការផ្តល់សក្ខីកម្មរបស់សាក្សី បានបញ្ជាក់ឲ្យឃើញថាបក្សកុំម្មុយនីស្តកម្ពុជា បាននាំស្រូវចេញយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន បើទោះបីជាប្រជាជនកម្ពុជារាប់ពាន់អ្នកត្រូវស្លាប់ដោយការអត់ឃ្លានក៏ដោយ ។ លើសពីនេះទៅទៀត សក្ខីកម្មរបស់ លោក រស់ ស៊ុយ បានបង្ហាញថា ខ្មែរក្រហមមានប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិរបស់ខ្លួន ដែលតម្រូវឲ្យបញ្ជូនស្រូវទៅកាន់ទីក្រុងភ្នំពេញ សម្រាប់ទុក និងរៀបចំនាំចេញទៅក្រៅប្រទេស ។ នៅពេលដែលមានបញ្ជាទិញស្រូវ ស្រូវទាំងនោះត្រូវបានដឹកជញ្ជូនទៅកាន់កំពង់សោម ដើម្បីធ្វើការនាំចេញ ។ អតីតកម្មករធ្វើការនៅកំពង់ផែកំពង់សោម ក៏បានអះអាងដែរ ថាខ្លួនបានលើដាក់ស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្នុងកប៉ាល់ជាច្រើន ដែលមើលទៅដូចកប៉ាល់របស់ចិន ។

## *សេចក្តីបញ្ចប់*

*បើទោះបីជា ការអត់ឃ្លានពុំត្រូវបានលើកយកមកពិភាក្សានៅក្នុងនៅក្នុងសំណុំរឿងថ្មីៗ ដែលផ្តើការចោទប្រកាន់ពីឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ យ៉ាងហោចណាស់ក៏តុលាការយោធាអន្តរជាតិបានយល់ថា ការចោទប្រកាន់ លោក ហាន់ ហ្វ្រែង ពីបទបង្កឲ្យមានការអត់ឃ្លាន និងលក្ខខណ្ឌរស់នៅមិនសមរម្យ ចំពោះប្រជាជនប៉ូឡូញ គឺជារឿងដែលត្រឹមត្រូវ ។ បើទោះបីជា ការជំនុំជម្រះនេះ បានធ្វើឡើងប៉ុន្មានទសវត្សរ៍មុនឆ្នាំ១៩៧៥ក៏ដោយ នៅក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន ការបង្កឲ្យមានការអត់ឃ្លានអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិបាន ។ ជាក់ស្តែង ការប្រព្រឹត្តរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ទៅលើប្រជាជនប៉ូឡូញ មានលក្ខណៈស្រដៀងគ្នាទៅនឹងការគ្រប់គ្រងរបស់ខ្មែរក្រហម ។*

*ជាមួយគ្នានេះដែរ សក្ខីកម្មនាពេលថ្មីៗនេះ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានផ្តល់ព័ត៌មានបន្ថែមទៅលើបញ្ហានៃការផលិត និងការនាំស្រូវចេញពីប្រទេសកម្ពុជាក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ជាសរុប ប្រសិនបើសក្ខីកម្មរបស់ លោក រស់ ស៊ុយ ជាការពិត នោះសបញ្ជាក់ឲ្យឃើញថា ខ្មែរក្រហមពិតជាបានរៀបចំប្រព័ន្ធមួយ សម្រាប់ប្រមូល ស្តុក ផលិត និងនាំស្រូវចេញទៅបរទេស ។*

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកបទសម្ភាសន៍ជាមួយអ៊ំប្រុស ប្រាជ្ញ ថេង អំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ សម្ភាសដោយ សុខ វីរៈ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ នៅខេត្តកែប ។ )*

<u>*ប្រាជ្ញ ថេង*</u>

*ខ្ញុំបាទឈ្មោះ ប្រាជ្ញ ថេង ទីលំនៅ ឃុំព្រៃធំ ស្រុកកំពត ខេត្តកំពត ។ ជំនាន់ លន់ នល់ ខ្ញុំរស់នៅស្រុកកំណើតសព្វថ្ងៃ ។ ខ្ញុំមានគ្រួសារហើយ ។ ខ្ញុំមានកូនពីរហើយ ។ ឆ្នាំ៧១ ៧២ ខ្ញុំអាយុ ២៤ ហើយ ។ ជំនាន់ហ្នឹង ខ្ញុំធ្វើទាហាន លន់ នល់ ។ ហើយខ្ញុំឆ្លងទៅដល់ប្រទេសវៀតណាម នគរចម្ប៉ា ចុះញ៉ាត្រាង ចុះយន្តហោះ៥៦ទៅ ។ ចុះញ៉ាត្រាងហើយ ជិះអាម៉ាសេកង់ដប់ ទៅដល់នគរចម្ប៉ា ដល់ទឹកពុះ ទឹកហុយ ។ ទឹកហ្នឹងក្តៅដល់ ៣០អង្សារ ដាក់ពងទាពងមាន់អាចឆ្អិន ។ ទៅរៀននៅហ្នឹងប្រមាណ ៣ខែ ។ ទៅរៀនធ្វើសង្គ្រាម ច្បាំងជាមួយខ្មែរក្រហម ។ ខ្ញុំធ្វើទាហាននៅក្រុងកែប ។ រួចហើយគេបញ្ជូន គេរើសទ័ពយកទៅ ។ ច្រើនណាស់ ម៉ាកែប ប្រមាណ ២០០នាក់ ។ មកវិញនៅធ្វើទ័ព វៃជាមួយខ្មែរក្រហម ។ ដល់ ៧៣ ពាក់កណ្តាលដើមខែ បែកក្រុងកែប ខ្ញុំក៏រត់ចុះកាត់សមុទ្រ*

ទៅកំពង់សោម ចេញពីទាហាន។ ដល់ឡើងពីកំពង់សោម ៧៨ ខ្ញុំឡើងតាមព្រែកចាក ខ្ញុំជិះឡានពួកយៀកកុង ឡើងមកកំពង់ត្រាច។ ដល់កំពង់ត្រាច ខ្ញុំដើរមកព្រៃធំ មកដល់វាំងណាក់ចង្អេរ មកនៅជាមួយខ្មែរក្រហម នៅហ្នឹង។ មកហ្នឹង ធ្វើស្រែនៅក្នុងក្រុមប្រវាស់ដៃ រួចមកគេដាក់បាយរួម។ ពេលបាយរួមហ្នឹង គេប្រើទាំងយប់ទាំងថ្ងៃ។ ដល់ក្រោយមកគេឲ្យដឹកជញ្ជូនសម្ភារៈ ដូចជា ដឹកស្រូវកិនយកអង្ករមកឲ្យគេហូប។ ដល់ក្រោយ គេឲ្យយើងភ្ជួរស្រែ។ ដល់យើងធ្វើការល្អ គេចេះតែឲ្យនៅទៅ។ ទៅភ្ជួរស្រែម៉ោង៣ ទៅភ្ជួរស្រែរាល់ថ្ងៃអញ្ចឹងទៅ ដល់ម៉ោង១១ ទើបគេឲ្យឈប់។ ហើយម៉ោង១ចាប់ភ្ជួរទៀត ដល់ម៉ោង៣ល្ងាច ទើបឲ្យឈប់ទៀតទៅ។ ហើយយប់ឡើងបើត្រូវស្ទូង គេឲ្យយើងទៅរែកកណ្ដាប់ ដូចថាម៉ាស្ទីកបីនាក់ ត្រូវរែកឲ្យហើយ រែកដាក់ម៉ារយម៉ែត្រពីហ្នឹងអញ្ចឹងទៅ យើងរែកដាក់កន្លែងឲ្យហើយអស់ បានសម្រាក។ ម៉ោង១០អញ្ចឹង បានសម្រាកវិញ។ ដល់រដូវប្រាំង ខែប្រូតអញ្ចឹង ថ្ងៃប្រូត យប់ឡើងបោក។ បោកហើយត្រូវគេឲ្យដេកចាំស្រូវ ដេកចាំទៅ។ ប្រពន្ធនៅផ្ទះ។ ព្រលឹមឡើងមកវិញមក។ មួយថ្ងៃ គិតទៅវា ៨ម៉ោង ហើយអានោះ ៤ម៉ោងទៀត ១២ម៉ោង។

<u>សំណួរ</u>: អញ្ចឹងធ្វើការមួយអាទិត្យតែម្ដង? ៧ថ្ងៃ?

<u>ចេង</u>: មួយអាទិត្យពេញ។ ៧ថ្ងៃ ឡើងដល់១៤ថ្ងៃហើយ។ ចុះបើធ្វើមួយព្រឹកទល់ល្ងាច ហើយ៧យប់ចាប់ធ្វើទៀត ចាប់ដល់ម៉ោង១០ ១១ទៀត។ គិតទៅ ម៉ាខែ ចង់ចូលពីរខែហើយ។ ប្រជាជនខ្លះទៅទាស់អញ្ចឹងទៅ ខ្លះទៅឈឺអញ្ចឹងទៅ។ ផ្ទះមួយគ្រួសារមួយ ផ្ទះជិតហ្នឹងមួយគ្រួសារមួយអញ្ចឹងទៅ។ មួយគ្រួសារៗ តែមិនបាននៅជួបជុំគ្នាទេ។ ជួនកាលប្ដីនៅផ្ទះ។ ប្ដីដឹកសម្ភារៈអញ្ចឹងទៅ ប្រពន្ធជួនកាលទៅត្រពាំងល្ពៅ ទៅទួលខ្ពស់ ទៅជិតវាលរេញ ទៅប្រូតស្រូវ។ កំណត់ទៅមួយខែបានវិលវិញក៏មានដែរ។ កំណត់ មិនថាអ្នកឯងឈឺទេ។ គ្រួសារខ្ញុំកើតគ្រាក់កូប ភ្នែកល្ងិត បានគេឲ្យមកវិញ។ អាហ្នឹងធ្វើបាបហើយ ជិះជាន់។ កូនបីនៅលើខ្ញុំទាំងអស់។ អាមួយនោះទើបតែបាន១៥ខែនៅជាមួយខ្ញុំ នៅប៉ៅ។ គេឲ្យម៉ែទៅ អញ្ចឹងគេទុកកូននៅហ្នឹង។ ខ្ញុំនៅធ្វើការផង នៅមើលកូនអញ្ចឹងទៅ។ ជំនាន់នោះ វាមិនស្រណុកទេ លំបាករហូត។ របបខ្មែរក្រហម ឆ្នាំ៧៨ ខ្ញុំគេឲ្យភ្ជួរស្រែ គេឲ្យរែកកណ្ដាប់ ដល់យូរទៅ គេឲ្យដឹកសម្ភារៈសេដ្ឋកិច្ច ដឹកត្រី ដឹកក្ដាម ដឹកមឹក បង្គា គ្រប់មុខ យកមកឲ្យគេ។ ដឹកត្រី កន្ទេព យកមកឲ្យប្រជាជន។ គេចែកឲ្យប្រជាជនហូប នៅក្នុងសហករណ៍។ ខ្ញុំមួយថ្ងៃពីរដើងបីដើង ដឹកបន្លែ។ មិនស្រណុកទេ ការងារហ្នឹង។ បាយព្រឹក បាយល្ងាច។ កង់ដឹកជាងមួយរយគីឡូអីជាង ជំនាន់ហ្នឹង។ គេឲ្យដឹកអញ្ចឹង ពេលយកមកដល់ យើងបែងចែកឲ្យគេទៅ ម៉ារោង៧០គីឡូ ៥០គីឡូ។ កាលហ្នឹងយើងធ្វើ យើងនៅក្រោមបញ្ជា គេទុកយើងជាផ្ញើរដែរ ៧៨។ គេហៅផ្ញើរ គេហៅត្រៀម កាលពីមុន។ វ៉ៃសម្លាប់ចោលដូចតែគ្នា។ តែវាឆាប់បែកទៅ វានៅរស់។

ហើយយើងធ្វើការល្អទៅ វាគ្រាន់បើ។ បើ ៦០០នាក់ ដាក់ត្រី ១០គីឡូ។ ព្រលឹមឡើង ដឹកបន្លែ ត្រឡាច ល្ពៅ បើអត់ទេ ទៅកាប់ព្រលិត ត្រកួន យកមកដាក់មួយរទេះគោ។ បើអត់ទេ យើងកាត់ ចេកគ្រាប់យកមកស្ង។ បើព្រលិតវិញ គ្មានបកទេ ហាន់ទាំងសំបក ហើយចេក ពុំវា បកយកអាណា ក្រហមៗចេញទៅ យកបណ្ដូលខៀវៗ ហាន់ស្ងទៅ។ បង់ម្ហូទៅ។ ហើយត្រីកិ ក៏ប្រជាជនយើង យ៉ាប់ហូបដែរ។ អាកូនកិតូចៗហ្នឹង គេស្ងោ ហើយគេជ្រយក កន្ទ្រងនំបញ្ចុក ជ្រយកសាច់ កុំឲ្យធ្លាក់ ឆ្អឹង ជ្រយកសាច់មកស្ង ហើយបង់ម្ហូអំពិល។ អត់ស្ករអំពិល ដាក់ផ្លែអំពិល បង់ហើយ ហូបទៅ។ ដល់រដូវខែស្ពង ខែពិបាកហើយ។ បាយម្នាក់មួយពេលមួយចៀម មិនថាក្មេងចាស់ គាត់មិនយូរទេ សល់តែស្បែកនិងឆ្អឹងទេ។ ដល់ចុងក្រោយបង្អស់ ដំឡូងតែបីខាំទេ បីខាំមិនបានប៉ុនកដៃយើងទេ ប្រវែងនេះហ្នឹង ហូតអត់ឆ្អែតទេ ហើយនឹងសម្លព្រលិត។ ដល់ចុងក្រោយទៀត ត្រូវពោតមក គេឲ្យ ពោតប៉ុនកដៃបី ពោតក្រហម មិនបានប៉ុន្មានទេ។ ដល់យូរៗទៅ ដាច់អាហ្នឹងទៅ អង្ករ ស្រូវ សម្ភារៈ ជញ្ជូនយកអស់ទៅ ខ្វះយើង ជញ្ជូនយកទៅព្រៃអស់។ ស្រូវបោកហើយ យប់ឡើងឡានរៀប ដឹកទាំង ឡានៗយកទៅអស់ហើយ។ ដឹកហ្នឹង ដឹកយកទៅព្រៃ មិនដឹងដឹកយកទៅណា។ ប្រហែលទៅជំរុំ ទៅភ្នំ លះបង់ក៏មិនដឹង។ ឃើញស្រូវនៅភ្នំលះបង់អញ្ចឹង ខ្ញុំឮគេនិយាយ ទាំងឃ្លាំងៗនៅភ្នំលះបង់។ ទៅភ្នំ ឆ្ងាយៗ គេយកសម្រាប់ចិញ្ចឹមទ័ព។ អញ្ចឹងវាដាច់ ខ្វះអង្ករ។ ស្ករត្នោតអីពេញៗពាង យប់ឡើងយក ជញ្ជូនទៅអស់ហើយ។ ដឹកទៅអស់ហើយ។ ដឹកទាំងឃ្លាំងៗដឹកទៅអស់ហើយ។

<u>សំណួរ</u>: ចុះអំរបបអាហារហ្នឹងនរណាគេជាអ្នកកំណត់ឲ្យប្រជាជន?

<u>ចម្លើយ</u>: កំណត់ហ្នឹងគឺអង្គការ។ មិនដឹងមួយណាអង្គការ យើងមិនដឹងដែរ គេថា អង្គការកំណត់។ គិត ទៅវាមិនមែនមកពីអង្គការ មកពីអ្នកធំជាន់ថ្នាក់លើៗហ្នឹងមក។ គេកំណត់មួយហិចតាបីតោន បើធ្វើ មិនបានបីតោន អញ្ចឹងគេដកពីប្រជាជនយកទៅឲ្យកងទ័ពទៅ។ សុខចិត្តប្រជាជនដែលអត់ទៅ យកទៅ ចិញ្ចឹមទ្យពទៅ។ ចុះទ័ពធ្វើសង្គ្រាម មិនឲ្យសំបូរទ័ព។ ប្រជាជនបេះតែធ្វើទៅ អាណាធ្វើមិនកើត ផាប់ ចោលទៅ។

<u>សំណួរ</u>: អនាម័យ មានបង្គន់ មានអី?

<u>ចម្លើយ</u>: អត់មានបង្គន់ អត់មានអីទេ។ បង្គន់ក្នុងព្រៃ។ អត់មានអនាម័យអីទេ។ ដើរអញ្ចឹងទៅ បត់ ជើងក្នុងព្រៃអញ្ចឹងតែម្ដង អត់មានកន្លែងអនាម័យ កន្លែងអីទេ។ បើនៅផ្ទះហ្នឹង អាចមានអនាម័យ។ ដូចស្រីៗអី ត្រូវរែកអាចម៍ៗយកទៅលាយនឹងអាចម៍គោ ចាក់ស្រែអញ្ចឹងទៅ។ ជំនាន់ហ្នឹងអញ្ចឹង។ ដូចថា ទៅធ្វើការផាប់អញ្ចឹង ដឹកក្រលុក កប់នៅនឹងព្រៃហ្នឹងទៅ យកទៅណាទៀត ផាប់ហើយ យក ទៅធ្វើអី។ គេនិយាយតែអ្នករស់ អ្នកធ្វើកើតទេ។ អ្នកធ្វើមិនកើតគេនិយាយធ្វើអី។ បើជម្ងឺ មានតែ

ជម្ងឺគ្រុនញាក់អញ្ចឹង ឬក៏គ្រុនក្តៅអញ្ចឹងយកទៅពេទ្យទៅ។ បើជាក៏ជាទៅ មិនជាងាប់ទៅ។ អាណា ត្រូវចាក់ថ្នាំ ចាក់ម្ជុល ចាក់ទឹកដូងអញ្ចឹង បូមទឹកដូង បូមចូល ងាប់ទៅ ក៏មានទៅ។ អាខ្លះបូមទឹកចូល អញ្ចឹងទៅ ងាប់អញ្ចឹងទៅក៏មាន ជំនាន់ហ្នឹង។ ពេទ្យគេមាន ពេទ្យមណ្ឌលសុខភាពគេហ្នឹង អាថ្នាំបុស ឈើ ខ្មៅៗដូចអាចម៍ទន្សាយអញ្ចឹង អត់មានថ្នាំអីស(ពណ៌)ទេ។ បើអ្នកឯងបន្តិចឈឺៗ យូរឡើងចូល ក្រលុកដូចតែគ្នាទេ វ៉ៃចោលដូចតែគ្នាហ្នឹង។ អ្នកឈឺក៏វ៉ៃចោលដែរ។ ជំនាន់ហ្នឹង គេឲ្យយើងធ្វើដើមគរ កុំនិយាយពីរឿងគេ កុំចេះដឹងពីរឿងគេ។ យើងសុខចិត្តធ្វើគរ ថ្លង់។ ខ្ញុំបងប្អូន ៧នាក់ ស្លាប់អស់ ២ នៅសល់ ៥។ ឲ្យតែអ្នក-១៧ វ៉ៃចោលទាំងអស់ហ្នឹង។ អត់មានសល់ទេ។ ម៉ាឃុំព្រៃធំ បើតាមខ្ញុំ ឃើញ។ សល់តែមេម៉ាយទេ។ ភូមិខ្ញុំ ៣០គ្រួសារ ប្រុសតែ ៧នាក់ទេ។ ហើយអ្នកណាដឹងរឿងគេ ក៏អត់បានដែរ។ ដឹងរឿងគេត្រូវស្លាប់ដូចគ្នា។ ចេះដឹងខុសរឿង គេយកយើងធ្វើទោសទៀតហើយ។

<u>សំណួរ</u>: ជំនាន់ហ្នឹងការហូបចុកចោទបញ្ហាខ្លាំងទេ?

<u>ចេង</u>: ខ្លាំង។ ប្រជាជនងាប់ច្រើនណាស់។ ប្រជាជនដាច់បាយ។ បើដំបូង ហូបបាយមួយចាន ដល់ចុងក្រោយមកហូបដំឡូងមីតែបីខាំ។ បើយើងឆ្លៀត នៅក្រោយផ្ទះយើងមានដំឡូង យើងលួចដាក់ក្នុង ឆ្នាំង កំសៀវអីដាក់ស្ងោរ។ បង្កាត់ភ្លើងនៅលើផ្ទះហ្នឹង ស្ងោរទៅ។ អាចហូបបានហើយ។ កូនចៅ យើង លួចហូបទៅ។ បើគេដឹងរឿងទៀត។ ម៉ាផ្ទះ យ៉ាងច្រើនមានកំសៀវមួយទេ អត់មានចាន មានឆ្នាំង អត់ទេ គេប្រមូលដល់អស់រលីង។ គេយកទៅដាក់រួមអស់ហើយ ឆ្នាំងចានអី។ ខ្ញុំបែកក្លាម ខ្ញុំធ្វើនេសាទ វ៉ៃមោង ដាក់លបក្តាម ទូកនេសាទចែវ។ ដល់កូនធំបន្តិចមក វាមានទូកមានម៉ាស៊ីន អញ្ចឹងទៅ។ ៥ឆ្នាំមុន។ ឥឡូវខ្ញុំឈប់ហើយ។ ខ្ញុំឈប់រកស៊ី ខ្ញុំចាស់ហើយ។ កុំថា បើមិនមានរបប ហ្នឹង យើងមិនបែកបាក់បងប្អូនកូនចៅមាក្លេអីទេ។ សព្វថ្ងៃ បើកុំតែសង្គមវាទៅអញ្ចឹងទៅ ស្លាប់ អស់។ មិនដឹងធ្វើយ៉ាងម៉េចទេ។

នេះជាចុងបញ្ចប់នៃវគ្គទី៨ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌកឯកសារកម្ពុជា ដែលនិយាយពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម។ នៅក្នុងការផ្សាយនៃវគ្គបន្ទាប់ យើងខ្ញុំនឹងពិភាក្សាអំពីសំណុំរឿងចាស់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងគ្រោះទុរភិក្ស និងការបង្អត់អាហារ។

*មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោជតសម្លេង។*

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និង ម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។